E20-18

# ការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍



##ករណីសិក្សា

នៅឧទ្យានជាតិព្រះសីហនុ " រាម " ក្រុងព្រះសីហនុ

និងដែនជំរកសត្វព្រៃពាមក្រសោប ខេត្តកោះកុង

នៃព្រះរាជាណាចក្រកម្ពុជា


ស្រាវជ្រាវ និងចងក្រងដោយៈ

លោក ជ័យ ទេពវត្តា

លោក សោម ជា

លោក ស៊ុយ ធា

លោក ទៀង សំអាត

សំរបសំរួលដោយៈ

អ្នកស្រី សូ ស្រីចំ

លោក អ៊ុក លី ឃីម


២០០២

ម.ព.ឯ.ក AIDOC

Code: 143-036

Date:

Donated by:

# ការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍

## ករណីសិក្សា

### នៅឧទ្យានជាតិព្រះសីហនុ "រាម " និងដែនជំរកសត្វព្រៃ "ពាមក្រសោប"

### នៃព្រះរាជាណាចក្រកម្ពុជា


**ស្រាវជ្រាវ និងចងក្រងដោយ**

លោក ជ័យ ពេជរតនា

លោក សោម ជា

លោក ឡេង សំអាត

**សំរបសំរួលដោយៈ**

អ្នកស្រី សូ ស្រីមុំ

លោក អ៊ុក លី឴ ឃីម


**២០០២**

គំរោងគ្រប់គ្រងធនធានតំបន់ឆ្នេរដោយផ្អែកលើសហគមន៏ (CBNRM) ចំនួនពីរ បានធ្វើនៅក្នុងឧទ្យានជាតិរាម (RNP) និងដែនជំរកសត្វព្រៃពាមក្រសោប (PKWS) គឺជាគំរូដំបូង នៃគំរោងគ្រប់គ្រងធនធានតំបន់ឆ្នេរដោយមានការចូលរួម នៅក្នុងប្រទេសកម្ពុជា។ មានអង្គការ និងអ្នកផ្តល់ជំនួយផ្សេងៗដូចជា UNDP, WI, CZM, IDRC បានគាំទ្រគំរោងដែលបានធ្វើនៅក្នុងឧទ្យានជាតិរាម។ ចំពោះគំរោងដែលបានធ្វើនៅក្នុងដែនជំរកសត្វព្រៃ"ពាមក្រសោប" គឺគំរោងការគ្រប់គ្រងធនធានព្រៃកោងកាងដោយមានការចូលរួម ត្រូវបានផ្តល់ថវិកាដោយ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសកាណាដា (IDRC). ដំណើរការនៃការងាររៀបចំសហគមន៏ ដែលនឹងធ្វើការពិភាក្សានៅក្នុងករណីសិក្សានេះ គឺផ្អែកទៅលើសកម្មភាពប្រចាំថ្ងៃរបស់អ្នកភូមិ និងការងារនៃក្រុមគំរោង។ ក្រុមការងារបានប្រមូលពតិមាន និងធ្វើអោយកាន់តែប្រសើរឡើងតាមរយៈកិច្ចប្រជុំផ្សេងៗ ការសំភាសន៏ និងការពិភាក្សាតាមរយៈការអនុវត្តន៏នៃគំរោងនីមួយៗ។

ទោះបីជាគំរោងទាំងពីរនេះ ជាគំរូដំបូងនៃការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយផ្អែកលើសហគមន៏ ដែលការចងក្រងឯកសារ ត្រូវបានគេទទួលស្គាល់ថាជា សមាសភាគដ៏សំខាន់នៃការរួមចំណែក និងការវិភាគសកម្មភាពគំរោងទាំងនេះ និងសំរាប់ការផ្សព្វផ្សាយពតិមាននេះដល់សហគមន៏មូលដ្ឋានផ្សេងៗទៀត និងដល់ស្ថាប័នពាក់ព័ន្ធដែលធ្វើការទាក់ទងទៅ នឹងការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយផ្អែកលើសហគមន៏។ ទាក់ទងទៅនឹងការទទួលស្គាល់នេះគំរោងទាំងពីរបានចាប់អារម្មណ៏ សហប្រតិបត្តិការជាមួយ គំរោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម (គំរោងនេះផ្តល់ថវិកាដោយ IDRC/WWF &OA) ដែលគោលបំណងរបស់គំរោងនេះ ផ្តោតលើការចងក្រងឯកសារស្តីអំពី គំរោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត ការធ្វើការងារជាមួយការសរសេរករណីសិក្សា អំពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមលើកដំបូងបានផ្តល់ឱកាសដល់គំរោងទាំងពីរ និងអ្នកភូមិដែលធ្វើការទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម (CBNRM) ដើម្បីរៀនជំនាញសរសេរបន្ថែមទៀត និងដើម្បីតភ្ជាប់បណ្តាញជាមួយគំរោង និងអ្នកភូមិផ្សេងៗទៀតដែលធ្វើការទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមក្នុងប្រទេសកម្ពុជា។

**ស្រាវជ្រាវ និងចងក្រងករណីសិក្សាដោយៈ**

**លោក ជ័យ ពេជ្ររតនា**

អនុប្រធានមន្ទីរបរិស្ថាន ខេត្តកោះកុង

**លោក សោម ផា**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកោះកុង

**លោក ឡេង សំអាត**

ការិយាល័យជលផល ក្រុងព្រះសីហនុ

**អ្នកសំរបសំរួលដោយៈ**

**អ្នកស្រី សូ ស្រីមុំ**

មន្ត្រីសមភាគីរវាងក្រសួងកសិកម្ម និងគំរោងស្តីពី " ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍"

នៃអង្គការ WWF

**លោក អ៊ុក លីយីម**

មន្ត្រីសមភាគីរវាង ក្រសួងបរិស្ថាន និងគំរោង "ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង"

**ទីប្រឹក្សា**

**លោក គីម ណាង**

**លោក តូ ប៊ីឌាស៊ិន**

**កញ្ញា ម៉ាលីសា**

**កែសំរួលករណីសិក្សា**

**កញ្ញា ម៉ាលីសា**

**លោក ទិនណិត វឿប៊ី**

**ឧបត្ថម្ភដោយអង្គការៈ**

គំរោង "ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង" (PMMR)

គំរោងស្តីពី " ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍" នៃអង្គការ WWF

គំរោងគ្រប់គ្រងតំបន់ឆ្នេរ (CZM)

មជ្ឈមណ្ឌលស្រាវជ្រាវសំរាប់អភិវឌ្ឍន៍អន្តរជាតិ (IDRC)

អុកស្វាមអាមេរិកាំង

មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់ (RECOFTC)

## អារម្ភកថា
## ដំណើរការសរសេរករណីសិក្សា

ដោយទទួលស្គាល់ថា ការគ្រប់គ្រងធនធានដោយសហគមន៍ (CBNRM) គឺជាទស្សនៈ និងការអនុវត្តន៍ថ្មីមួយ ចំពោះប្រទេសកម្ពុជា ការចងក្រងឯកសារអំពីបទពិសោធន៍មូលដ្ឋាន និងមេរៀនដែលទទួលនេះ បង្កើតចេញជាសមាសភាគសំខាន់មួយ នៃការវិភាគ និងការចែករំលែកពត៌មានរវាងសហគមន៍មូលដ្ឋាន គំរោង និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ ដែលធ្វើការទាក់ទង CBNRM នេះ។

ការចងក្រងករណីសិក្សានេះ គឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរៀនសូត្រចម្រុះមួយ (ដោយផ្អែកលើគំរូវដ្តរៀនសូត្រដែលជាបទពិសោធន៍មួយ) ដែលមានរយៈពេលចាប់ពីខែ មិថុនា ឆ្នាំ ២០០១ ដល់ ខែវិច្ឆិកា ឆ្នាំ ២០០២ និងអាចមានរយៈពេលយូរជាងនេះទៅទៀត។ ការបណ្តុះបណ្តាលដំបូងអំពីការសរសេរករណីសិក្សាដែលបានធ្វើឡើង នៅខេត្តសៀមរាបសំរាប់អ្នកអនុវត្តគំរោង CBNRM ជាង ៣០នាក់ នៅខែកក្កដា ឆ្នាំ ២០០១ ដើម្បីផ្តល់ជំនាញគ្រឹះ សំរាប់ការសិក្សាស្រាវជ្រាវ PRA ការវិភាគពត៌មាន ការសរសេរអត្ថបទ និងចងក្រងឯកសារ។ ជាលទ្ធផល នៃតម្រូវការខ្ពស់សំរាប់ការងារប្រភេទនេះ វគ្គបណ្តុះបណ្តាល ករណីសិក្សាមួយបានធ្វើឡើងនៅ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅខេត្តរតនៈគិរី ដែលមានអ្នកចូលរួមជាង ៤០ នាក់ ដើម្បីបង្កើនជំនាញខាងការស្រាវជ្រាវ និងជំនាញសរសេរអត្ថបទ នឹងដើម្បីផ្តួចផ្តើមបង្កើតជាក្របខ័ណ្ឌការងារដែលជាទស្សនទានមួយសំរាប់ការងារ CBNRM នៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផលបានមកពីការបណ្តុះបណ្តាលនេះ យើងបានរៀបចំផែនការការងារករណីសិក្សាមួយដែលមានបញ្ចូលទាំងការកំណត់ប្រធានបទ និងសេចក្តីព្រាងគំនិត ។

ករណីសិក្សានេះ គឺជាផ្នែកមួយនៃករណីសិក្សាចំនួន ១០ ធ្វើការផ្តោតទៅលើទាំងបញ្ហាជលផល និងបញ្ហា ព្រៃឈើ ដែលបានបង្កើត ឡើងនៅក្នុងភូមិសាស្ត្រសំខាន់ ៤ នៃប្រទេសកម្ពុជាដែលមាន តំបន់ខ្ពង់រាប (ខេត្តរតនៈគិរី និងមណ្ឌលគិរី) តំបន់ទំនាបកណ្តាល (ខេត្តពោធិ៍សាត់ និងកំពង់ឆ្នាំង) តំបន់ទន្លេមេគង្គ ឬទន្លេសាប (ខេត្តស្ទឹងត្រែង និងខេត្តសៀមរាប) និងតំបន់ឆ្នេរ (ខេត្តកោះកុង និងកំពង់សោម)។

តាមករណីជាច្រើនសេចក្តីព្រាងលើកទី១ របស់ករណីសិក្សាទាំង១០ ត្រូវបានបង្កើតឡើងដោយក្រុមស្រាវជ្រាវ និងអ្នកនិពន្ធចម្រុះដោយចាប់ពី ខែមករា ដល់ខែមេសា ឆ្នាំ ២០០២។ សេចក្តីព្រាងលើកទី២ ត្រូវបានលើកយកមកបង្ហាញ ដើម្បីទទួលយកនូវការផ្តល់យោបល់ក្នុងពេលធ្វើសិក្ខាសាលា និងសិក្ខាសាលាបូកសរុបដែលបានធ្វើនៅខេត្តកោះកុងក្នុង ខែ ឧសភា ឆ្នាំ២០០២។ នៅពេលនោះករណីសិក្សាទាំងនេះត្រូវបានពិនិត្យមើលបកប្រែជាភាសាអង់គ្លេស ហើយបានធ្វើការកែសម្រួល ដើម្បីបោះពុម្ព និងផ្សព្វផ្សាយ។ អ្នកសំរបសំរួលគំរោងនៅតាមមូលដ្ឋានដើរតួនាទីឈានមុខ ក្នុងការជ្រើសរើសប្រធានបទសម្រាប់ការសិក្សាស្រាវជ្រាវ ការប្រមូលពត៌មាន និងការសរសេរអត្ថបទ។ អ្នកសម្របសម្រួល

និងទីប្រឹក្សាថ្នាក់ជាតិផ្តល់ជាជំនួយលើការពិនិត្យមើលគំរោងករណីសិក្សា ការវិភាគពតិមាន ការបកប្រែ និងការកែសម្រួល ។

ដោយធ្វើការតាមគំនិតផ្តួចផ្តើមនេះ បានផ្តល់ឱ្យអ្នកចូលរួមក្នុងកម្រិតផ្សេងៗគ្នានូវឱកាសរៀនជំនាញបានកាន់តែច្រើន ដើម្បីចែករំលែកបទពិសោធន៍ជាមួយគំរោង និងមនុស្សផ្សេងៗ ដែលធ្វើការខាងការងារ CBNRM នៅទូទាំងប្រទេសកម្ពុជា។ តាមមធ្យោបាយបែបនេះ គំនិតផ្តួចផ្តើមចងក្រងករណីសិក្សា CBNRM ត្រូវបានគេប្រើជាឧបករណ៍មួយសម្រាប់បង្កើតជាបណ្តាញការងារ និងចែករំលែកមេរៀនដែលទទួលបាន។ ករណីសិក្សាទាំងនេះនឹងត្រូវ បានគេចែករំលែកផងដែរនៅតាមវេទិកានានាដូចជា សិក្ខាសាលា CBNRM ដែលនឹងធ្វើនៅខែ វិច្ឆិកា ឆ្នាំ ២០០២។ គេរំពឹងទុកថាលទ្ធផលនេះនឹងត្រូវបានប្រើប្រាស់ដើម្បីជាពតិមានដល់ការបង្កើតគោលនយោបាយទៅថ្ងៃមុខនៅក្នុងប្រទេសកម្ពុជា ។

# មាតិកាអត្ថបទ

## ការគ្រប់គ្រងធនធានតំបន់ឆ្នេរមានការចូលរួមពីសំណាក់សហគមន៍នេសាទ បាននាំមកនូវការកាត់បន្ថយសកម្មភាពនេសាទខុសច្បាប់ និងការកើនឡើងធនធានក្នុងតំបន់ដែលសហគមន៍បានចូលរួមការពារ


អារម្ភកថា ........ ៣

១-សេចក្តីផ្តើម: ........ ៧

២- ដំណើរការគ្រប់គ្រងសហគមន៍នេសាទនៅឧទ្យានជាតិព្រះសីហនុ "រាម" និង នៅដែនជំរកសត្វព្រៃពាមក្រសោប ........ ៨

   ២.១-មូលហេតុដែលនាំឱ្យមានការបង្កើតសហគមន៍នៅតំបន់ទាំងពីរ: ........ ៨

      ក-ចំនុចខុសគ្នា ........ ៩

      ខ-ចំនុចដូចគ្នា ........ ១០

   ២-២-ដំណើរការរៀបចំសហគមន៍ ........ ១០

      ២.២.១-ប្រវត្តិនៃការបង្កើតសហគមន៍នៅតំបន់ទាំងពីរ ........ ១០

      ២.២.២- ការរៀបចំក្រុម និងគណៈកម្មការសហគមន៍ ........ ១៤

      ២.២.៣- ការរៀបចំលក្ខន្តិកៈ និង បទបញ្ញត្តិ ........ ១៤

   ២.៣-ការគ្រប់គ្រងសហគមន៍នេសាទ: ........ ១៥

      ២.៣.១-រៀបចំផែនការគ្រប់គ្រង ........ ១៥

      ២.៣.២ ពីការធ្វើផែនការនិងបទបញ្ញាតិសហគមន៍ដែលបានចែងមកការអនុវត្តជាក់ស្តែង ........ ១៦

៣. សន្និដ្ឋាន និងអនុសាសន៍: ........ ២១

តារាងឧបសម្ព័ន ........ ២៣

ឧបសម្ព័នទី១ : ប្រវត្តិគំរោង **PMMR** ........ ២៣

ឧបសម្ព័នទី២ : គំរោង ការគ្រប់គ្រងតំបន់ឆ្នេរដោយសហគមន៍ នៅរាម ក្រុងព្រះសីហនុ ........ ២៥

ឧបសម្ព័នទី៣ : គំរោងករណីសិក្សាការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ........ ២៧

## ការគ្រប់គ្រងធនធានតំបន់ឆ្នេរមានការចូលរួមពីសំណាក់សហគមន៍នេសាទ បាននាំមកនូវការកាត់បន្ថយសកម្មភាពនេសាទខុសច្បាប់ និងការកើនឡើងធនធានក្នុងតំបន់ដែលសហគមន៍បានចូលរួមការពារ

### ១.សេចក្តីផ្តើមៈ

ព្រះរាជាណាចក្រកម្ពុជាមានឆ្នេរប្រវែង ៤៣៥ គ.ម លាតសន្ធឹងចាប់ពីប្រទេសថៃដល់ប្រទេសវៀតណាម គ្របដណ្តប់លើខេត្តក្រុងចំនួន៤គឺ ខេត្តកោះកុង ក្រុងព្រះសីហនុ ខេត្តកំពត និងក្រុងកែប ដែលមានប្រជាជនរស់នៅប្រមាណ ៨៤៥.៥០០ នាក់ (MoE ១៩៩៨) ក្នុងចំណោមនោះភាគច្រើនបានពឹងពាក់ទាំងស្រុងទៅលើធនធានជលផល សំរាប់ការរស់នៅប្រចាំថ្ងៃ។ តំបន់ឆ្នេរកម្ពុជាសំបូរទៅដោយធនធានមានជាអាទិ៍ ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម ត្រី គ្រប់ប្រភេទសត្វព្រៃ ប្រជុំកោះ និងឆ្នេរខ្សាច់ជាដើម។ ប៉ុន្តែធនធានទាំងនេះពីមួយឆ្នាំទៅមួយឆ្នាំមានការថយចុះជាលំដាប់ដោយសារកំណើនប្រជាជន ការគ្រប់គ្រងមិនបានល្អ និងការប្រើប្រាស់មានភាពអានាធិបតេយ្យ។ កំឡុងឆ្នាំ ១៩៩៣ ក្រោយពេលកម្ពុជាប្រកាន់យករបបប្រជាធិបតេយ្យ សេរីពហុបក្ស តំបន់ឆ្នេរ ពិសេសខេត្តកោះកុង ត្រូវរងនូវសំពាធនៃ ការហូរចូលប្រជាពលរដ្ឋពីខេត្តក្នុងតំបន់ទំនាបកណ្តាល ដែលសង្ឃឹមថាជីវភាពរបស់ពួកគេនឹងមានភាពល្អប្រសើរអាស្រ័យ ដោយធនធានធម្មជាតិតំបន់ឆ្នេរ (PMMR Rept. 2000)។

ដោយតំរូវការទីផ្សារចេះតែកើនឡើងនិងដោយមានការឃុបឃិតពីសំណាក់អ្នកមានអំណាច និងអ្នកមានប្រដាប់



ព្រៃកោងកាងដែលបានកាប់បំផ្លាញ (ពាមក្រសោបៈ១៩៩៩)

អាវុធផង ភាពអានាធិបតេយ្យនៃការទាញយកធនធានបានកើនឡើងខ្លាំង ដូចជា ការនេសាទខុសច្បាប់ ការកាប់រានព្រៃកោងកាងធ្វើអាជីវកម្ម ធ្វើធ្យូង ធ្វើជាស្រែបង្គា ស្រែក្តាម ចំការដំណាំ ផ្ទះសំណាក់ លំនៅដ្ឋាន។ល។ ដូចគ្នានេះដែរ រាមនិងពាមក្រសោបដែលជាតំបន់ការពារធម្មជាតិនៅតំបន់ឆ្នេរ ក៏រងនូវការបំផ្លាញយ៉ាងដំណំដែរ ទោះបីជាមានការខិតខំប្រឹងប្រែង ទប់ស្កាត់ពីស្ថានប័នជំនាញបរិស្ថាន និងជលផលក្តី។ ចំណែកឯការគ្រប់គ្រង របស់ស្ថាប័នជំនាញពុំមានប្រសិទ្ធិភាពទេដោយខ្វះខាតលើមធ្យោបាយ សំភារៈ និងថវិកា សំរាប់អនុវត្តការងារ។ បន្ថែមពីនេះទៀត មិនមានកិច្ចសហការល្អរវាងស្ថាប័ននានា និងអាជ្ញាធរមូលដ្ឋាន។ ម្យ៉ាងវិញទៀតមានភាពត្រួតស៊ីគ្នានូវតួនាទីនៃបណ្តាអង្គភាពពាក់ព័ន្ធនានា។ ឯច្បាប់( ក្រិត្យច្បាប់លេខ៣៣) ហួសសម័យសំរាប់អនុវត្តនាពេលបច្ចុប្បន្ន។

ប្រជាពលរដ្ឋមិនយល់អំពីរបៀបនៃការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។ លើសពីនេះទៀត ការគ្រប់គ្រងកន្លងមកធ្វើឡើងតែស្ថាប័នជំនាញប៉ុណ្ណោះ ឯប្រជាពលរដ្ឋដែលរស់នៅ និងប្រើប្រាស់ផ្ទាល់ពុំត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងដំណើរការគ្រប់គ្រងឡើយ។

ដូច្នេះ តើគួរមានការលើកទឹកចិត្តឱ្យប្រជាពលរដ្ឋមូលដ្ឋានបានចូលរួមគ្រប់គ្រងធនធានតំបន់ឆ្នេរ ជាមួយរដ្ឋាភិបាលដែររឺ យ៉ាងណា? ហើយតើពួកគាត់ចូលរួមដោយរបៀបណា ?

ការចូលរួមរបស់សហគមន៍មូលដ្ឋាន អ្នកពាក់ព័ន្ធ និងស្ថាប័ននានា និងការផ្តល់សិទ្ធិអំនាចដល់ប្រជាពលរដ្ឋ គឺជាគន្លឹះដ៏សំខាន់ដែលមិនអាចខ្វះបានក្នុងការគ្រប់គ្រងធនធានតំបន់ឆ្នេរ។

## ២. ដំណើរការគ្រប់គ្រងសហគមន៍នេសាទនៅឧទ្យានជាតិព្រះសីហនុ "រាម" និងនៅដែនជំរកសត្វព្រៃពាមក្រសោប

### ២.១. មូលហេតុដែលនាំឱ្យមានការបង្កើតសហគមន៍នៅតំបន់ទាំងពីរ:

គំរោងរាមនិងពាមក្រសោបគឺជាគំរោងការចូលរួមគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍មុនគេបង្អស់នៅតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាគឺកកើតឡើងនៅអំឡុងឆ្នាំ១៩៩៨ ។

ក្នុងកាលៈទេសៈដែលធនធានធម្មជាតិ កំពុងត្រូវរងនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ។ នៅរាមមានអង្គការ ETAP/UNDP បន្ទាប់មកគឺ និងបច្ចុប្បន្នគឺ DANIDA CZM ជាអ្នកឧបត្ថម្ភ ឯនៅពាមក្រសោបមាន គំរោង "ការចូលរួមគ្រងធនធានព្រៃកោងកាង (PMMR/IDRC)" ជាអ្នកឧបត្ថម្ភ។

មានកត្តាសំខាន់ៗមួយចំនួន( ដូចគ្នានិងខុសគ្នា) ដែលជំរុញឱ្យគំរោងទាំងពីរកកើតឡើង។

## គ. ចំនុចខុសគ្នា

| តំបន់រាម | តំបន់ពាមក្រសោប |
|---|---|
| • ការធ្វើនេសាទបែបអណាធិបតេយ្យដោយប្រើប្រាស់ឧបករណ៍ឈិបយន្តហៅខុន អួនអូស អូសគ្រែងឈាមដោយ ម៉ាស៊ីន នៅតំបន់ឆ្នេរទឹករាក់ដែលភាគច្រើនអ្នកប្រើប្រាស់ឧបរកណ៍ទាំងនោះមកពីតំបន់ខាងក្រៅ ។<br>• ប្រជានេសាទបាត់បង់ដែននេសាទ ដែលធ្វើឱ្យអ្នកខ្លះចាកចេញ ទៅធ្វើនេសាទរឺប្រកបរបរផ្សេងៗនៅតំបន់ដទៃទៀត ។<br>• អ្នកនេសាទជាលក្ខណៈគ្រួសារធ្លាប់បានរួមគ្នាតវ៉ាប្រឆាំងសកម្មភាពឈិបយន្ត ។ | • ការកាប់រានព្រៃកោងកាងយ៉ាងអណាធិបតេយ្យ ធ្វើជាស្រែបង្គានិងផលិតជាធ្យូងដើម្បីនាំចេញទៅបរទេសដែលនាំឱ្យអន្តរាយដល់ធនធានព្រៃកោងកាងនិងធនធាននេសាទ ។<br>• ទាំងស្ថាប័នជំនាញ ទាំងអាជ្ញាធរមូលដ្ឋានគ្មានលទ្ធភាពជន្លៀសប្រជាជនចេញពីតំបន់ ។ |



ទូករុញ (រាមៈ ១៩៩៨ )

ខាងក្រោមជាអំណះអំណាងបញ្ជាក់ពីការខុសគ្នា

អ្នកស្រី **រី យ៉ះ** នៅភូមិដូនលយជាអ្នកភាវរគ្រែងដោយដៃលើកឡើងថា :

*អំឡុងឆ្នាំ១៩៩៨ គឺជាឆ្នាំដែលយើងជាអ្នកភាវរគ្រែងដោយដៃជួបការពិបាកខ្លាំងណាស់ ព្រោះដែនដែលយើងធ្លាប់រកស៊ី ក្រៅពីត្រូវវងនូវការអូស រុញពីទូកម៉ាស៊ីននោះ ក៏ត្រូវគេព័ទ្ធយកដើម្បីធ្វើជាកន្លែងចិញ្ចឹមគ្រែងឈាម ។ ដោយដែនដែលធ្លាប់រកស៊ីត្រូវគេព័ទ្ធយកដូចនេះ ពួកយើងត្រូវបង្ខំចិត្តចុះទៅភាវនៅទឹកជ្រៅ ហើយខ្លះត្រូវចាកចេញពីភូមិខ្លួនទៅតំបន់ផ្សេងទៀត ដូចជា ថ្មស អណ្តូងទឹកជាដើម ។*

លោក**សៀក សាបុន** អ្នកមកពីខេត្តព្រៃវែងសព្វថ្ងៃជាអ្នកនេសាទនៅភូមិកោះកាងបានបញ្ជាក់ថា:

*ពួកយើងស្ទើរតែទាំងអស់ជាអ្នកមកពីតំបន់ទំនាបកណ្តាលនៅក្រោយឆ្នាំ១៩៩០ ដោយមានមុខរបរកាប់ព្រៃកោងកាងធ្វើធ្យូង ។ ហើយនៅឆ្នាំ១៩៩៨ ព្រៃទាំងនោះបានហិនហោចស្ទើរតែអស់ ។ ក្នុងពេលនោះ ជីវភាពយើងមានការលំបាកណាស់ ។ យើងមិនអាចវិលត្រលប់ទៅស្រុកវិញបានទេ ព្រោះយើងបានលក់ដីនៅទីនោះអស់ហើយ ។ ដូចនេះជំរើសរបស់យើងគឺមានតែការពារនិងស្តារឡើងវិញនូវព្រៃកោងកាង ដែលរិចរិលនេះ ដើម្បីទាញយកផល ពីព្រៃនេះដោយធ្វើយ៉ាងណាឱ្យមានលក្ខណៈយូរអង្វែង ។*

### ខ. ចំនុចដូចគ្នា

- ធនធានជលផល( ត្រី បង្គា កោងកាង) មានការថយចុះយ៉ាងខ្លាំង ។
- ការរស់នៅរបស់ប្រជាពលរដ្ឋពឹងផ្អែកតែលើការទាញយកផលពីធនធានធម្មជាតិតំបន់ឆ្នេរ ។
- ជីវភាពប្រជានេសាទកាន់តែលំបាកទៅៗ និងថែមទាំងជំពាក់បំណុលទៀតផង ។

## ២.២.ដំណើរការរៀបចំសហគមន៍

### ២.២.១.ប្រវត្តិនៃការបង្កើតសហគមន៍នៅតំបន់ឆាំឆពីរ

### ផែនទីបង្ហាញពីទីតាំងធ្វើករណីសិក្សានៅ តំបន់ពាមក្រសោប និងឧទ្យានជាតិព្រះសីហនុ "រាម"




នៅតំបន់ដែនជំរកសត្វព្រៃពាមក្រសោបមានសហគមន៍ចំនួនពីរត្រូវបានបង្កើតឡើងនៅក្នុងភូមិចំនួនពីរកោះកាងនិងកោះស្រឡៅ។ ប៉ុន្តែនៅឧទ្យានជាតិរាមវិញមានសហគមន៍នេសាទតែមួយដែលចូលរួមដោយភូមិចំនួន១០។ ភាពខុសគ្នានេះគឺមកពីទីតាំងភូមិសាស្ត្រត្រូវធ្វើការគ្រប់គ្រង។ នៅរាមជាទូទៅប្រជានេសាទទាំង១០ភូមិពួកគេធ្វើនេសាទក្នុងដែនតែមួយ ឯនៅពាមក្រសោបពួកគាត់ទាំងពីរភូមិធ្វើនេសាទក្នុងដែនផ្សេងគ្នាដែលមានអូរ ព្រែកជា ព្រំប្រទល់។

**រាមៈ** ដោយធនធានកំពុងត្រូវរងនូវការបំផ្លាញយ៉ាងធ្ងន់ធ្ងរ ផលនេសាទថយចុះព្រមទាំងបាត់បង់ ដែននេសាទផងនោះ នៅកំឡុងខែ កុម្ភៈ ឆ្នាំ ១៩៩៨ ប្រជានេសាទដែលមានឧបករណ៍តូចតាចនៅតំបន់រាម(ពិសេសភូមិស្រែចាមលើ ភូមិស្រែក្នុង ភូមិអូរជ្រៅ)បានធ្វើការតវ៉ា បះបោរ ចំពោះការនេសាទដោយឈិបយន្ត រហូតដល់មានការកាប់កំទេចដង ឈិបយន្តទៀតផង។ ដោយការបោះបោរមានទ្រង់ទ្រាយកាន់តែធំ លោកអភិបាលខ័ណ្ឌព្រៃនប់បានចុះធ្វើអន្តរាគមន៍



ការពិភាក្សារបស់អ្នកសំរបសំរួលសហគមន៍មូលដ្ឋានឧទ្យានជាតិព្រះសីហនុ "រាម" ដែនជំរកសត្វព្រៃ "ពាមក្រសោប"
និងសហគមន៍នៅអង្គការហ្វាវ ក្នុងកំឡុងពេលធ្វើទស្សនៈកិច្ចសិក្សានៅខេត្តសៀមរាប ឆ្នាំ២០០០

ដោយឱ្យសមត្ថកិច្ចជំនាញ និងកំលាំងប្រដាប់អាវុធសហការចុះបង្ក្រាប់បទល្មើសនេសាទនេះ។ តែទង្វើរនេះគឺដូចជាភ្លើងចំបើងប៉ុណ្ណោះ ដែលប៉ុន្មានសប្តាហ៍ក្រោយមកបទល្មើសកើតឡើងវិញដដែល។ ដែននេសាទដែលប្រជានេសាទតូចតាច រកស៊ីគឺស្ថិតនៅក្នុងឧទ្យានជាតិរាមដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ឧទ្យានុរក្ស។ ទោះជាមានការខិតខំទប់ស្កាត់ពីឧទ្យានុរក្សក៏ដោយ ក៏បទល្មើសនេសាទនៅតំបន់នេះនៅតែជាបញ្ហាក្តៅគគុកដដែល ដោយសារកង្វះខាតមធ្យោបាយក្នុងការចេញបង្ក្រាប ពិសេសគឺគ្មានការចូលរួមពីសំណាក់ប្រជានេសាទ។ ឧទាហរណ៍ មានតែឧទ្យានុរក្សប៉ុណ្ណោះដែលចូលរួមការល្បាត ឯអ្នកពាក់ព័ន្ធផ្សេងទៀតមិនបានចូលរួមឡើយ។ ដោយមើលឃើញនូវភាពចន្លោះប្រហោង ដូចនេះឧទ្យានជាតិដែលមានគំរោង ETAP កំពុងឧបត្ថម្ភនោះបានចាប់ផ្តើមធ្វើការសិក្សាពីលទ្ធភាពនៃការដាក់បញ្ចូលប្រជា នេសាទក្នុងកិច្ចគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់។ បន្ទាប់ពីត្រូវបានជួបពិភាក្សាមានប្រជានេសាទខ្លះបានស្ម័គ្រចិត្តចូល រួមល្បាតជាមួយឧទ្យានុរក្ស។

លោក ប៉ាន់ ញឿនបច្ចុប្បន្នជាអនុប្រធានសហគមន៍ភូមិស្រែក្នុងលើកឡើងថាៈ

*កាលណោះ(ចុងឆ្នាំ១៩៩៨) យើងមានចិត្តរីករាយណាស់ដោយខាងឧទ្យានជាតិបានមកពិភាក្សាជាមួយពួកយើង ដោយចង់ឱ្យមានចូលរួមគ្រប់គ្រងធនធាននេសាទរួមគ្នារវាងសហគមន៍ ក៏ដូចជាស្ថាប័នដទៃទៀតជាមួយ និងឧទ្យានជាតិ។ ហើយយើងក៏ស្ម័គ្រចិត្តឥតរុញរាដោយចាប់ផ្តើមចូលរួមល្បាតជាមួយឧទ្យានុរក្ស ព្រោះណាមួយយើងកំពុងជួបការលំបាកយ៉ាងខ្លាំងក្នុង ការរកទទួលទានពីការនេសាទ។*

ខណៈដែលអ្នកភូមិខ្លះស្ម័គ្រចូលរួមល្បាត ការរៀបចំក្រុម និងការជ្រើសរើសគណៈកម្មការក៏ដំណើរការដែរ ដោយផ្ដើមធ្វើនៅភូមិចំនួន៦មុន។ បន្ទាប់មកដំណើរការចងក្រងលក្ខន្តិកៈ និងបទបញ្ញាតិសហគន៍។ មុននឹងធ្វើការចងក្រងល័ក្ខន្តិកៈ គំរោងបានរៀបចំឱ្យមានទស្សនៈកិច្ចសិក្សាដល់គណៈកម្មការនេសាទភូមិ ទៅកាន់គំរោងការដាំព្រៃកោងកាងខេត្តកំពត និងការគ្រប់គ្រងដែននេសាទទឹកភាក់(ទីដែលមានគ្រែងឈាម) នៅភូមិថ្មស ខេត្តកោះកុង។

ពាមក្រសោបៈ គំរោង(PMMR)បានចំណាយពេលច្រើន(ជំហ៊ាន១: ចុងឆ្នាំ១៩៩៧ ដល់ពាក់កណ្ដលឆ្នាំ២០០០) ធ្វើការសិក្សាស្រាវជ្រាវពីការប្រើប្រាស់ធនធានដោយសហគមន៍ កសាងទំនាក់ទំនងរវាងគំរោងជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធជុំវិញខេត្ត និងសហគមន៍មូលដ្ឋាន ហើយលើកកំពស់ការយល់ដឹងដល់ពួកគេ ដោយរៀបចំឱ្យមានសិក្ខាសាលាវគ្គបណ្ដុះបណ្ដាលនៅមូលដ្ឋាន ទស្សនៈកិច្ចសិក្សាទៅកាន់គំរោងនានាក្នុងនិងក្រៅប្រទេស។

ទទួលបានបទពិសោធន៍និងចំណេះដឹងពីវគ្គ ក៏ដូចជាដំណើរទស្សនៈកិច្ចសិក្សា ពួកគាត់មានការចាប់អារម្មណ៍ពីសារៈសំខាន់នៃការចូលរួមរបស់ប្រជានេសាទក្នុងការគ្រប់គ្រងធនធានជលផល ហើយក៏ចាប់ផ្ដើមរៀបចំចងក្រងលក្ខន្តិកៈ និងបទបញ្ញាតិសហគមន៍ ជ្រើសរើសជាក្រុម និងគណៈកម្មាការ (ដើមឆ្នាំ២០០១)។ ជាដំបូងគេបានជ្រើសរើសគណៈកម្មការបណ្ដោះអាសន្នចំនួន៣នាក់ ពីក្នុងចំណោមមនុស្សសំខាន់ៗ ដើម្បីពង្រាងលក្ខន្តិកៈជាមួយក្រុមគំរោង មេភូមិ និងស្ថាប័នជំនាញ។ បន្ទាប់ពីបានពង្រាងនៅថ្នាក់ភូមិហើយដំណើរការរៀបចំជ្រើសរើសគណៈកម្មាធិការ និងក្រុមក៏បានដំណើរការ។

គំរោងទាំងពីរបានយកចិត្តទុកដាក់ក្នុងការជ្រើសរើសមនុស្សសំខាន់ៗ មកពីចំណោមស្ត្រី និងពីអ្នកកាន់សាសនាដទៃដែលមានក្នុងសហគមន៍។ ការឱ្យមានការចូលរួមរបស់ស្ត្រី និងសាសនាដទៃទៀតក្នុងភូមិសំដៅលើកកំពស់សិទ្ធស្ត្រី ក្នុងការ



ការបោះឆ្នោតរើសគណៈកម្មការសហគមន៍ ក្នុងដែនជំរកសត្វព្រៃពាមក្រសោប ឆ្នាំ ២០០០

ចូលរួមការងារសហគមន៍ ម្យ៉ាងទៀតស្ត្រីមានទំនាក់ទំនងដោយផ្ទាល់ជាមួយសកម្មភាពសហគមន៍ ឯសាសនា ទៀតសោត ក៏មានឥទ្ធិពលក្នុងការប្រៀនប្រដៅដល់សមាជិកសហគមន៍ផងដែរ ។

### ២.២.២. ការរៀបចំក្រុម និងគណៈកម្មាការសហគមន៍

ដំណើរការនេះត្រូវបានចូលរួមនិងទទួលស្គាល់ពីអាជ្ញាធរភូមិ ឃុំដោយមានការសំរបសំរួលពីគំរោង។ នៅពាម ក្រសោប ជាតំបូងយើង(គំរោង)បានធ្វើការជ្រើសរើសមនុស្សសំខាន់ៗចំនួន២៥ នាក់នៅកោះស្រឡៅ និង១២នាក់នៅ កោះកាង ដែលបន្ទាប់មក៣នាក់ក្នុងចំណោមពួកគេក្នុងភូមិនីមួយៗ ត្រូវជ្រើសរើសឱ្យធ្វើគណៈកម្មាការបណ្តោះអាសន្ន ដើម្បី សំរបសំរួលជាមួយស្ថាប័នជំនាញ អាជ្ញាធរដែនដី និងគំរោងក្នុងការចងក្រងលក្ខន្តិកៈ និងបទបញ្ញាតិសហគមន៍។

អនុលោមតាមខដែលបានចែងក្នុងលក្ខន្តិកៈ សមាជិកគណៈកម្មាការចំនួន៧នាក់និង៣នាក់សំរាប់ភូមិ កោះស្រឡៅ និង កោះកាង ត្រូវបានបោះឆ្នោតជ្រើសរើសដោយអ្នកភូមិ។ រួចហើយគណៈកម្មាការនេះ ជាអ្នករៀបចំក្រុមដោយខ្លួនឯង ដោយ ក្រុមនីមួយៗ មានពី២០ ទៅ ៣០គ្រួសារ ដែលនៅផ្ទះជិតជាមួយគ្នា។

ចំណែកឯនៅរាមវិញ បន្ទាប់ពីជ្រើសរើសមនុស្សសំខាន់ៗនិងរៀបចំជាក្រុម(មានសមាជិកពី១៥ ទៅ ៣០ គ្រួសារ និងមានឧបករណ៍នេសាទដូចគ្នា)ហើយសមាជិកគណៈកម្មាធិការចំនួនបីរូប(ប្រធាន អនុប្រធាន និងបេឡា) ត្រូវបានបោះ ឆ្នោតជ្រើសរើសតាមភូមិនីមួយៗដែលឱ្យឈ្មោះថា គណៈកម្មាការសហគមន៍នេសាទភូមិ។ ដោយសារ ភូមិទាំង១០ បង្កើតជា សហគមន៍តែមួយសហគណៈកម្មាការសហគមន៍នេសាទត្រូវបានបង្កើតដែលមានសមាជិកមកពី ប្រធានគណៈកម្មការនៃភូមិ នីមួយៗ។ រួចហើយទើបគេចងក្រងលក្ខន្តិកៈនិងបទបញ្ញាតិជាក្រោយ។

វចនាសម្ព័ន្ធ




### ២.២.៣. ការរៀបចំលក្ខន្តិកៈ និង បទបញ្ញតិ

ជារួមតាមរយៈបទពិសោធន៍ដែលបានមកពីទស្សនៈកិច្ចសិក្សា និងឯកសារនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង សហគមន៍នេសាទត្រូវបានយកមកសិក្សាដើម្បីជាមូលដ្ឋានសំរាប់ដំណើរការចងក្រងលក្ខន្តិកៈនិងបទបញ្ញាតិរបស់ សហគមន៍។

ក្រោយពេលដែលបានពង្រាងនៅថ្នាក់មូលដ្ឋានហើយ លក្ខន្តិកៈនិងបទបញ្ញត្តិក៏ត្រូវបានដាក់ឱ្យមានការពិភាក្សានៅក្នុងសិក្ខាសាលាដែលចូលរួមដោយមន្ទីរពាក់ព័ន្ធ និងអាជ្ញាធរដែនដី។ ពង្រាងនេះត្រូវបានចំណាយពេលប្រហែល៤ខែ (មានការពិភាក្សាចំនួន២ដងសំរាប់ពាមក្រសោប និង៤ដងនៅរាមក្នុង១ខែ)។ ពង្រាងលក្ខន្តិកៈនៅពាមក្រសោបធ្វើឡើងដោយគណៈកម្មការបណ្ដោះអាសន្នមនុស្សសំខាន់ៗ មេភូមិ ដោយមានការសំរបសំរួលពីគំរោង រីឯរាម ពង្រាងនេះធ្វើឡើងដោយគណៈកម្មការសហគមន៍ដែលជាប់ឆ្នោតហើយ និងប្រធានក្រុម ព្រមទាំងការសំរបសំរួលពីគំរោង។

## ២.៣-ការគ្រប់គ្រងសហគមន៍នេសាទៈ

### ២.៣.១-រៀបចំផែនការគ្រប់គ្រង

វិធីសាស្ត្រនៃការរៀបចំផែនការគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍កោះស្រឡៅ និងកោះកាងដែលបានកំណត់យកនិងកំពុងអនុវត្តរាល់ថ្ងៃនេះគឺដកស្រង់ពីលទ្ធផលវគ្គបណ្ដុះបណ្ដាលសិក្ខាសាលាដែលធ្វើនៅខែមិថុនាឆ្នាំ២០០១ ស្ដីពីការគ្រប់គ្រងធនធានជលផលនៅក្នុងសហគមន៍ដោយមានការចូលរួម។ ផែនការដែលសហគមន៍ទាំងពីរបានផ្ដួចផ្ដើម មានៈ ការលប់បំបាត់សកម្មភាពនេសាទដោយឧបករណ៍ផ្ទូងផាង សកម្មភាពទូកឌុន កាប់បំផ្លាញព្រៃកោងកាង និងការដាំស្ដារព្រៃកោងកាងឡើងវិញ។

ដើម្បីឆ្លើយតបទៅនឹងផែនការធំៗនេះសហគមន៍ បានរៀបចំជាផែនការលំអិតដូចជាៈ

- ស្រង់ស្ថិតិម្ចាស់និងចំនួនផ្ទូងផាង និងទំនាក់ទំនងជាមួយអាជ្ញាធរភូមិ ឃុំ និងជំនាញជលផលដើម្បីដកបង្គោលផ្ទូងផាង
- បើកវគ្គបណ្ដុះបណ្ដាលរបៀបនៃការដាំកោងកាង ជ្រើសរើសពូជ កំណត់ពេលវេលានៃការជ្រើសរើសដាំ និង



ប៉ុស្តិ៍សហគមន៍ភូមិ កោះកាង ២០០២

ចុះសិក្សា ស្រាវជ្រាវទីកន្លែងដែលត្រូវដាំស្តារកោងកាង

- បែងចែកវេនល្បាត(០៨ដងនៅកោះស្រឡៅ និង ០៦ ដងនៅកោះកាងក្នុង ០១ខែ)
  និងចុះយាមល្បាតដើម្បីទប់ស្កាត់ សកម្មភាពទូកឌុន សកម្មភាពកាប់ព្រៃកោងកាង
- រៀបចំទំរង់ឯកសារដើម្បីតាមដានកត់ត្រាសកម្មភាពបទល្មើសនិងធ្វើរបាយការណ៍ប្រចាំខែ

ចំពោះការធ្វើផែនការគ្រប់គ្រងនៅសហគមន៍វាមចាប់ផ្តើមពីការប្រជុំពិភាក្សានៅក្នុងជួរគណកម្មការនេសាទទាំង ១០ ភូមិ ដោយរួមមានៈ លើកកំពស់ការយល់ដឹងការអប់រំបរិស្ថាន ទប់ស្កាត់បទល្មើសនេសាទ ។

ដើម្បីឆ្លើយតបទៅនឹងផែនការធំៗនេះ សហគមន៍មានផែនការ សកម្មភាពដូចជាៈ

- ផ្សព្វផ្សាយច្បាប់បរិស្ថាន ជលផល លក្ខន្តិកៈបទបញ្ញត្ត បទដ្ឋានផ្សេងៗ តាមរយៈការប្រជុំ ពិភាក្សា ចែកខិត្តប័ណ្ណ អប់រំ និងតាមរយៈទូរទស្សន៍ក្រុងជាដើម
- រៀបចំផ្លាកសញ្ញានិងខ្លឹមសារអប់រំបរិស្ថាននៅក្នុងចំណុចសំខាន់ៗមួយចំនួនរបស់សហគមន៍
- រៀបចំស្នាក់ការទប់ស្កាត់បទល្មើសនេសាទ
- បែងចែកវេនយាមល្បាតតាមភូមិនិមួយៗ (ភូមិនិមួយៗទទួលយាមល្បាត០៣ថ្ងៃ)
- កំនត់សមាសភាពចូលរួមល្បាត (សហគមន៍៤នាក់ ប៉ូលីស០១នាក់ ឧទ្យានុរក្ស ០១ នាក់ក្នុង០១ ថ្ងៃ)
- រៀបចំទំរង់ឯកសារដើម្បីតាមដានកត់ត្រាសកម្មភាពបទល្មើសនិងធ្វើរបាយការណ៍ប្រចាំខែ
- កំនត់ពេលវេលាធ្វើសកម្មភាពល្បាត(៤ដងក្នុង០១ អាទិត្យ)
- លប់បំបាត់ការដាក់របាំងព្រួល ។

### ២.៣.២ ពីការធ្វើផែនការនិងបទបញ្ញត្តិសហគមន៍ដែលបានចែងមកការអនុវត្តជាក់ស្តែង

សហគមន៍ទាំងពីរបានអនុវត្តការងារល្បាតនៅក្នុងដែនសហគមន៍នៅតាមចំណុចដែលតែងមានកើតបទល្មើសសំដៅកាត់បន្ថយបទល្មើសនានាក្នុងដែនសហគមន៍ ។ បន្ថែមពីនេះទៀត ដើម្បីងាយស្រួលដល់ដំណើរការល្បាតសហគមន៍ បានបង្កើតជំរកល្បាត (ប៉ុស្តិ៍យាមប្រចាំការ) សំរាប់ឃ្លាំមើលសកម្មភាពល្មើសនេសាទក្នុងដែនសហគមន៍ ។

ពាមក្រសោបៈ

រវាងសហគមន៍ដែលបង្កើតទាំងពីរមានការរៀបចំការល្បាតខុសគ្នា គេបានដាក់វេនគ្នាឱ្យចូលរួមល្បាតចំពោះសមាជិកសហគមន៍ទាំងអស់ ដោយមានគណៈកម្មការចែកវេនអ្នកទទួលខុសត្រូវដឹកនាំ ។ ឯភូមិកោះស្រឡៅវិញ មានតែគណៈកម្មការនិងប្រធានក្រុមទេដែលចូលរួមល្បាត ។

រយៈពេល៦ខែដំបូងគឺភូមិកោះកាង

លោក លី សុវណ្ណា ជាអ្នកប្រមូលទិញផលនេសាទក្នុងភូមិនិងជាប្រធានសហគមន៍ភូមិកោះស្រឡៅមាន យោបល់ចំពោះរឿងនេះថាៈ

> *ប្រជាជនបានបោះឆ្នោតឱ្យយើង ដូចនេះ យើងត្រូវឈានមុខធ្វើជាគំរូគេ ។ សហគមន៍មួយ រឹងមាំលុះ ត្រាតែអ្នកដឹកនាំមានការប្តេជ្ញាចិត្តធ្វើការងារ ត្រូវឆ្លៀតពេលដើម្បីជួយធ្វើការងារគ្នា ហើយត្រូវស្មោះត្រង់រវាងគ្នានិងគ្នា ។*

តែទោះជាយ៉ាងនេះក្តី ក៏ពួកគេទាំងពីរភូមិបានការចូលរួមពីឧទ្យានុរក្សគ្រប់ពេលល្បាត ឯប៉ូលីសឃុំត្រូវបានសុំ អន្តរាគមន៍នៅពេលមានបញ្ហាធំដំ។ ថ្វីត្បិតតែសហគមន៍បែងចែកការងារបានល្អហើយក្តី ពួកគេនៅតែត្រូវការចាំបាច់នូវការ

> *យើងជាគណៈកម្មការបានចំណាយពេលវេលាច្រើន ដោយត្រូវតាមហៅដល់ផ្ទះចំនួនពីរ រឺបីដង ពេលចុះល្បាតម្តងៗ។ មានមូលហេតុខ្លះៗ ដែលបណ្តាលឱ្យមានការលំបាកនេះ នោះគឺពួកគេភាគច្រើនមើលបំណាំគ្នា ហើយអ្នកខ្លះ (តិចតួច)ទៅនេសាទនៅទីឆ្ងាយដោយត្រូវដេកមួយអាទិត្យ រឺដប់ថ្ងៃទើបត្រលប់មកភូមិម្តង។ តែការលំបាកនេះបានធូរស្រាលបន្តិចម្តងៗ អាស្រ័យដោយការខិតខំរបស់ពួកយើងខ្ញុំជាគណៈកម្មាការ ព្យាយាមពន្យល់ គួបផ្សំនឹងការចុះជាប់របស់បងៗខាងគំរោងផង ធ្វើឱ្យពួកគាត់បានយល់ដឹងថា មានតែពួកគាត់ទេដែលទទួលផលពីធនធានទាំងនេះ។ ដូចនេះ ការចូលរួមការពារ ក៏មានតែពួកគាត់ដែរដែល មាន ប្រសិទ្ធិភាព ព្រោះពួកគាត់ចេញ ចូលទីនោះរាល់ថ្ងៃ។ ជាក់ស្តែងមានអ្នកនេសាទខ្លះពេលជួបបទល្មើស បានមករាយការណ៍ រឺក៏បានធ្វើការណែនាំអ្នកប្រព្រឹត្តល្មើសនោះទៀតផង។ ដោយមានការចូលរួមបែបនេះ ឃើញថាបទល្មើស ពិសេសការកាប់កោងកាងបានថយចុះ តែប្រសិនបើមាន ក៏ធ្វើឡើងក្នុងស្ថានភាពលួចលាក់បំផុត។*

សំរបសំរួលពីគំរោង ដើម្បីជួយបង្ហាត់បង្ហាញការងារល្បាត មានរបៀបកត់ត្រាពេលចុះល្បាត ធ្វើរបាយការណ៍ជាដើម។ ក្នុងន័យនេះ គំរោងបានចុះល្បាតជាប្រចាំជាមួយសហគមន៍នៅក្នុងយៈពេលមួយខែតំបូង។ បណ្តាខែក្រោយមកទៀត ពួកគេធ្វើដោយខ្លួនឯង។ ៦ខែក្រោយតំណើរការល្បាត ការប្រជុំពិភាគ្សារួមមួយត្រូវបានរៀបចំក្នុងគោលបំណង ពិនិត្យឡើងវិញពីការងារកន្លងមក ។កិច្ចពិភាក្សាពិនិត្យជាសំខាន់ទៅលើ"ការចូលរួមពីសំណាក់សមាជិក សហគមន៍ក្នុងការងារល្បាត " និង " បទល្មើសក្នុងដែនសហគមន៍ "។ លទ្ធផលបានបង្ហាញថា នៅភូមិកោះកាង មានប្រជានេសាទប្រមាណ ៨០ភាគរយបានចូលរួមល្បាតដោយផ្ទាល់ ឯភូមិកោះស្រឡៅមានប្រមាណជា ៣០ ភាគរយ។ ចំពោះបទល្មើសដែលគេបានជួបប្រទះភាគច្រើនគឺការកាប់ដើមកោងកាងធ្វើធ្យូង និងកាប់យកទៅលក់ធ្វើដោយអ្នកមកពីក្រៅសហគមន៍។ ឡធ្យូងដែលគេបានជួបតែងត្រូវបានវាយកំទេច ឯការកាប់កោងកាងយកទៅលក់ត្រូវបាន រឹបអូសនិងផាកពិន័យ។ ក្រៅអំពីកាប់កោងកាង បទល្មើសបន្ទាប់បន្សំមានដូចជា អួនអួស មងខូវ ចាប់សត្វស្លាបជាដើម។

លោក វង្ស តារា ប្រធានសហគមន៍ភូមិកោះកាងបានបញ្ជាក់អំពីការងារល្បាតថាៈ អ្វីដែលសំខាន់គឺថាសមាជិកសហគមន៍ដែលពីមុន ជាអ្នកកាប់កោងកាងធ្វើឡធ្យូង បានក្លាយមកជាអ្នកនេសាទហើយនាំគ្នាស្តារព្រៃកោងកាង ឡើងវិញតាមរយៈចូលរួមការពារនិងដាំឡើងវិញ។ តាមពតិមាន ជាដំបូងពួកគេមានការលំបាកណាស់ចំពោះការប្រែមុខរបរពីអ្នកដុតធ្យូងមកធ្វើជាអ្នកនេសាទ។ ទីមួយដោយសារពួកគេសុទ្ធសឹងជាអ្នកមកពីខេត្តផ្សេងៗ គេពុំមានជំនាញ លើការងារនេសាទនៅសមុទ្រទេ និងទីពីរគឺព្រៃកោងកាងដែលជាជំរក និងចំណីដ៏សំខាន់របស់មច្ឆាជាតិត្រូវបានបំផ្លាញយ៉ាងតំណំ ជាហេតុធ្វើឱ្យផលនេសាទបានតិចបំផុត។

អ្នកស្រី សុខ ហឿង ជាអ្នកនេសាទនិងជាសមាជិកគណៈកម្មាការសហគមន៏ភូមិកោះស្រឡៅបញ្ជាក់ថា

*ពួកយើងពិតជា លំបាកមែននៅពេលឈប់ធ្វើឡត្បូងថ្មីៗ តែឥឡូវនេះ ជីវភាពពួកយើងមានសភាពគ្រាន់បើជាង កាលពីយើងកំពុងធ្វើឡត្បូង ព្រោះព្រៃកោងកាងដុះឡើងវិញ ហើយធនធានផ្សេងៗ ពិសេសក្តាម ក៏កើនជាងមុន*

លោកវ៉េង សំសាក់ ជាអ្នកនេសាទរស់នៅតំបន់នេះតាំងពីដើមមកគាត់ធ្លាប់ជាអ្នកផលិតនិងទិញត្បូង ហើយបច្ចុប្បន្ន ក្លាយជាឧទ្យានុរក្សវិញ មានប្រសាសន៏ថា

*ខ្ញុំធ្លាប់ជជែកជាមួយអ្នកនេសាទដែលពីមុនពួកគេជាអ្នកធ្វើឡត្បូងមកពីខេត្តឆ្ងាយបានឱ្យដឹងថា ពួកគេនឹងមិនធ្វើជា អ្នកដុតត្បូទៀតទេ បើទោះជាគេមិនហាមប្រាមក៏ដោយ ព្រោះរបរដែលយើងកំពុងចាប់យកសព្វថ្ងៃមានលំនឹងជាង*



**តំបន់ដែលសហគមន៍បានដាំកោងកាងឡើងវិញ នៅកោះស្រឡៅឆ្នាំ ២០០០**

ក្រៅពីការងារល្បាត ការដាំព្រៃកោងកាងក៏ទទួលបានការចូលរួមគាំទ្រយ៉ាងច្រើនពីអ្នកភូមិដែរ។ ឧទាហរណ៏ ផែនការដែលគេរៀបចំដាំឆ្នាំ២០០១ សមាជិកសហគមន៏ដាំបាន ដល់ទៅ៤ហិកតា នៅកោះកាង នៅភូមិកោះកាងមាន២ ហិកតា និង កោះស្រឡៅ ៤។ លុះពេលអនុវត្តផ្ទាល់ និង៨ហិកតានៅកោះស្រឡៅ។

ទន្ទឹមនឹងនេះ សហគមន៏កំពុងជួបបញ្ហាមួយចំនួនទៀតនៅឡើយដែរ។ ក្នុងនោះមានៈ ផ្ទុងផាងដែលមានចំនួន ច្រើនរហូតដល់ទៅ៥០កន្លែង ស្មើនឹង៣១៣មាត់ (ទាំងក្នុងដែនសហគមន៏និងក្រៅ) ស្ថិតជាបញ្ហាដដែលនៅឡើយ។

មួយទៀតគឺ ការរុញកូនត្រីតឹកកែ និងចាប់លក់ ទិញកូនក្តាមជាដើម។ កន្លងមកផ្ទូងផាងត្រូវបានចាត់ទុកជាឧបករណ៍ ស្របច្បាប់ ដោយមានការយកពន្ធពីស្ថាប័នជលផលទៀតផង។ តែដោយសារការធ្វើជីវកម្មមានចំនួនច្រើនពេក ហើយធ្វើដោយមិនគោរពច្បាប់ វាបានជះឥទ្ធិពលមិនល្អដល់ជីវៈសាស្ត្រចំរុះ ក៏ដូចជាសង្គមដែរ គឺការធ្វើចរាចរណ៍ផ្លូវទឹក។ ដោយស្ថាប័នជំនាញមិនមានថវិកាគ្រប់គ្រាន់ ដើម្បីចាត់វិធានការណ៍ចំពោះផ្ទូងផាងនៅក្រៅដែន សហគមន៍នោះទើបបានជាសហគមន៍



**សកម្មភាពសហគមន៍ដាំកោងកាងឡើងវិញ ២០០២**

ពុំទាន់ចាត់វិធានការណ៍ផ្ទូងផាងក្នុងដែនសហគមន៍ ព្រោះវាមានភាពមិនស្មើគ្នាលើមុខរបរតែមួយ។ ឯរឿងរុញកូនត្រីតុកកែវិញ គេកំពុងតែរកដំណោះស្រាយដើម្បីឈានទៅរកការលប់បំបាត់សកម្មភាពរុញ (រុញធ្វើឱ្យបំផ្លាញ ដល់ស្មៅសមុទ្រ)។ គេមិនអាចបំបិទការរុញនេះភ្លាមទាំងស្រុងបានទេ ព្រោះអ្នកស្រុកភាគច្រើនកំពុងពឹងផ្អែករបរនេះ ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ តែទោះជាយ៉ាងណាក៏ដោយ គេកំពុងជ្រើសរើសយកវិធីសាស្ត្រមួយនោះគឺគេចាប់ផ្តើម ដោយទុកកន្លែងមួយ (១០០ហិតា) សំរាប់ជាជំរកត្រីដោយហាមសកម្មភាពរុញ។ ចំពោះការចាប់ ទិញ លក់កូនក្តាម ក៏ពុំទាន់មានការអនុវត្តជាក់ស្តែង ពិតប្រាកដនៅឡើយដែរ ព្រោះបញ្ញតិរបស់សហគមន៍ទើបតែបានការទទួលស្គាល់ពី អាជ្ញាធរនិងស្ថាប័នជំនាញ។ មានបញ្ហាមួយទៀតដែលធ្លាប់មាននៅសហគមន៍នេះដែរ គឺការចាប់ត្រីផ្សោតយកទៅចិញ្ចឹម ក្នុងសួនដើម្បីបំរើភ្ញៀវទេសចរពីក្រុមហ៊ុនមួយក្នុងខេត្ត ដោយពុំបានសុំយោបល់ពីសហគមន៍ឡើយ ហើយដែលសកម្មភាព នេះត្រូវបានហាមដោយបញ្ញតិរបស់សហគមន៍។ រឿងនេះធ្វើឱ្យសហគមន៍មានការព្រួយបារម្ភចំពោះអនាគតធនធានរបស់គេ ក្រោយពីគេខំការពារបានល្អ ពិសេសព្រៃកោងកាង ខ្លាចមានការរំលោភពីអ្នកខាងក្រៅទៀត។

ភាម: ជារួមរវាងផែនការដែលដាក់ចេញនឹងសកម្មភាពជាក់ស្តែងបានដំណើរទៅជាវិជ្ជមាន។ ជាក់ស្តែង ស្នាក់ការយាមល្បាតចំនួនបីត្រូវបានសាងសង់ឡើងនិងដាក់វេនគ្នាយាមជាប្រចាំ។ ឯការល្បាតបានធ្វើទៅតាមផែនការកំនត់ដោយមានការចូលរួម ពីសហគមន៍ ឧទ្យានុរក្សនិងប៉ូលីសសង្កាត់។

លោក រស់ ហាក់ ប្រធានសហគមន៍ភូមិអូជ្រៅមានប្រសាសន៍ថា:

> *ចាប់តាំងពីមានល្បាតជាប្រចាំមកឃើញថា សកម្មភាពអូសគ្រែងឈាម អួនអូស ឈិបយន្ត មានការថយចុះយ៉ាងហោចណាស់ក៏៦០ភាគរយដែរ បើប្រៀបធៀបទៅនឹងពេលមិនទាន់មានការចេញល្បាតដោយសហគមន៍។ ប្រជានេសាទតូចតាចរកដោយដៃផ្ទាល់ ហើយដែលធ្លាប់តែទៅរកស៊ីនៅតំបន់ផ្សេងៗ ក៏ត្រឡប់មកភូមិស្រុកវិញដែរ ព្រោះឥឡូវពួកគេអាចរកបាននៅទីនេះ ហើយចំពោះអ្នករកស៊ីរុញឈិបដោយដៃ រឺមងបង្កា ។ល។ ក៏ទទួលបានផលច្រើនជាងមុនដែរ គឺអាចដោះស្រាយការចំណាយប្រចាំថ្ងៃបាន។ បន្ថែមពីនេះទៀត ការរៀបចំជាសហគមន៍សំឡេងរបស់យើង ខ្លាំជាងមុន ដែលធ្វើឱ្យមានការគាំទ្រពីស្ថាប័ន និងអាជ្ញាធរច្រើនជាងពីកាលមិនទាន់រៀបចំជាសហគមន៍។*

អ្នកស្រី លី មុំ ប្រធានសហគមន៍ភូមិបឹងតាស្រីបានឯកភាពចំពោះមតិរបស់លោករស់ ហាក់ ដោយបានបន្ថែមថា:

> *ពិតមែនហើយ យើងទទួលបានផលប្រយោជន៍ពីការរៀបចំសហគមន៍នេសាទ ជាអាទិ៍ផលនេសាទមានការកើនឡើង។ តែយើងនៅជួបការលំបាកច្រើនទៀត ដូចជា: ការល្បាត ចូលរួមច្រើនតែគណៈកម្មការសហគមន៍ ឯសមាជិកសហគមន៍ពុំសូវមានមុខទេ។ នេះបញ្ជាក់ថា សហគមន៍ពុំទាន់រឹងមាំពិតប្រាកដអាចដំណើរការដោយខ្លួនឯងបានទេ បើគ្មានការគាំទ្រពីគំរោង។ ចំនែកឯបទល្មើសវិញ ការកាប់ព្រៃលិចទឹក វាតយកដីនៅតែមានជាបន្តបន្ទាប់ដែលភាគច្រើនធ្វើឡើងដោយអ្នកមានលុយមកពីខាងក្រៅសហគមន៍ ហើយបញ្ហានេះ យើងក៏បានធ្លាប់ដោះស្រាយជាបន្តបន្ទាប់មកដែរ ដោយសហការជាមួយសង្កាត់ និងឧទ្យានជាតិកោះ ហៅអ្នកកាប់មកធ្វើកិច្ចសន្យាបញ្ឈប់។ បញ្ហាមួយទៀត វាជាទំនាស់នៅក្នុងសហគមន៍រវាងអ្នកនេសាទប្រើមង លប និងឈិបរុញដោយដៃជាមួយ នឹងអ្នកនេសាទចាប់គី។ ពីដើមឡើយគេចាប់គីដោយប្រើឈិបរុញនឹងដៃ។ តែចាប់ពីឆ្នាំ១៩៩៦ គេឃើញមានការចាប់ ប្រើទូកម៉ាស៊ីនរុញដែលអ្នកទាំងនោះភាគច្រើនមកពីខេត្តឆ្ងាយៗរស់នៅភូមិកោះខ្យង។ ឧបករណ៍នេះអាចចាប់បានបង្គាខ្លះៗផងដែរ។*

ខាងសមត្ថកិច្ចជំនាញ ដោយឃើញពួកអ្នករុញគី ប្រើទូកតូចៗ ថែមទាំងចាស់ៗផងនោះ គេហាក់ពុំសូវយកចិត្តទុក ដាក់ហាមឃាត់ឡើយ ទោះជាគេដឹងថា ការចាប់នេះបានបំផ្លាញធនធានក៏ដោយ។ ហេតុនេះហើយ ទើបចំនួនអ្នករុញគីដោយទូកម៉ាស៊ីនមានការកើនយ៉ាងច្រើន ពិសេសអ្នកនេសាទនៅភូមិកោះខ្យង។ ដល់ពេលយើងធ្វើសហគមន៍ ពួកអ្នកនេសាទប្រើមង ឈិប ។ល។ បានទាមទារសុំឱ្យបញ្ឈប់ការរុញគីដោយម៉ាស៊ីននេះ ហើយត្រូវផាកពិន័យដូចទូកអូសគ្រែង រឺអួនអូសដែរ។ តែការអនុវត្តន៍ជាក់ស្តែង យើងធ្វើរឿងគីនេះមិនចេញសោះ នោះមកពីពួកគេមិនអាចផ្លាស់ប្តូរឧបករណ៍បាន។

លោក សេង ចាន្ថា ប្រធានសហគមន៍ភូមិស្រែចាមក្រោមមានយោបល់ថា:

*បញ្ហាស្ថិតត្រង់ថា ពួកអ្នកុរុញគីទាំងនោះមិនសូវមានបទពិសោធក្នុងការនេសាទនៅសមុទ្រទេ (ពួកគេទើបតែមកខេត្តផ្សេង) ហើយពួកគេភាគច្រើនក៏ជាប់បំណុលផង ។ តាមពិត យើងក៏ធ្លាប់បានរកដំណោះស្រាយខ្លះដែរ ដោយបានចែកដែនដោយឡែកសំរាប់ទូកគីនេះ តែដូចជាពុំសូវទទួលបានផលល្អទេ ដោយពេលខ្លះរំលោភការបែងចែកនេះដោយសំអាងថា ទីនោះមានឧបស័គ្គ ពិសេសនៅរដូវវស្សាទីដែលពួកគេរកស៊ីនោះមានរលកធំៗ ។ យើងធ្លាប់ជួបប្រទះនូវការប្រឈមមុខដាក់គ្នាក្នុងពេលយើងកំពុងល្បាតដោយអ្នកុរុញគីមិនព្រមឱ្យយើងដកហូតសំភារៈ ។ ពេលនោះយើង ក៏ទាំគ្នាថយត្រឡប់មកវិញ ព្រោះខ្លាចមាន អំពើហឹង្សាកើតមានឡើង ហើយរាយការណ៍ជូនសង្កាត់ ។*

សហគមន៍នេសាទរាម ក៏ដូចពាមក្រសោបដែរ ធ្លាប់បានធ្វើការផាកពិន័យចំពោះបទល្មើសដែលចាប់បានដែរ ពិសេសគឺឈិបយន្តនិងអួនអូស ។ តែការផាកនេះ គឺធ្វើឡើងដោយសហការយ៉ាងជិតស្និទ្ធជាមួយឧទ្យានជាតិ ។ ចំណែកឯការកាប់ព្រៃកោងកាងវិញ គេពុំដែលបានធ្វើការផាកពិន័យទេ ភាគច្រើនគឺមានការសំរបសំរួលពីអាជ្ញាធរមូលដ្ឋានឱ្យអនុវត្តត្រឹមធ្វើកិច្ចសន្យាបញ្ឈប់ ។

## ៣. សន្និដ្ឋាន និងអនុសាសន៍:

ក៏ដូចជាបណ្តាលប្រទេសដទៃទៀតដែរ ការគ្រប់គ្រងធនធានធម្មជាតិ និយាយជារួម និងការគ្រប់គ្រងតំបន់ឆ្នេរនិយាយដោយឡែក ត្រូវបានគេអនុវត្តនៅប្រទេសកម្ពុជាដើម្បីលើកកំពស់ការគ្រប់គ្រងធនធានទាំងនេះ ។ ទោះបើនេះជាការគ្រប់គ្រងបែបថ្មីក៏ដោយ ក៏មកទល់ពេលនេះ គេឃើញមានលទ្ធផលវិជ្ជមានមួយចំនួនដែរ ។ ជាក់ស្តែង កិច្ចសហការណ៍រវាងអាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងប្រជានេសាទ កាត់បន្ថយបទល្មើស និងការកើនឡើងនៃធនធានក្នុងដែនសហគមន៍ ។ ក្នុងន័យនេះ ដោយបានទទួលនូវសិទ្ធិក្នុងកិច្ចការពារធនធានសហគមន៍ នៅរាម និងពាមក្រសោប បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញនៅនឹងកន្លែងចុះល្បាតទប់ស្កាត់បទល្មើស ដែលនាំឱ្យមានការថយចុះនូវបទល្មើសក្នុងដែនសហគមន៍គ្រប់គ្រង ។ លើសពីនេះទៀត សមត្ថភាពរបស់សមាជិកសហគមន៍ ពិសេសគណៈកម្មការត្រូវបានពង្រឹងតាមរយៈទស្សនៈកិច្ចសិក្សាវគ្គបណ្តុះបណ្តាល និងការងារប្រចាំថ្ងៃរបស់ខ្លួន ហើយសិទ្ធិរបស់សហគមន៍ក្នុងការចូលរួមគ្រប់គ្រងធនធានត្រូវបានទទួលស្គាល់ជាបណ្តើរៗ ។ ជាក់ស្តែងលក្ខន្តិកៈនិងបទបញ្ញាតិសហគមន៍រាម និងពាមក្រសោបត្រូវបានទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ។

ជាមួយនឹងលទ្ធផលដែលទទួលបានទាំងនេះ ក៏នៅមានបញ្ហាមួយចំនួនដែលទាមទារឱ្យមានការចូលរួមដោះស្រាយ ។ បញ្ហាទាំងនោះ មានជាអាទិ៍: ការយល់ដឹងរបស់សមាជិកសហគមន៍ ក្នុងកិច្ចការគ្រប់គ្រងធនធាននៅមានកំរិតជាដើម ។ យើងទទួលស្គាល់ថា ក្នុងដំណើរការរៀបរៀងលក្ខន្តិកៈនិងបទបញ្ញាតិ មានតែមនុស្សសកម្មមួយចំនួន និងគណៈកម្មការក្នុងសហគមន៍ទេ ដែលបានចូលរួមពិភាក្សាជាមួយគំរោង ផ្នែកជំនាញ និងអាជ្ញាធរមូលដ្ឋាន ។ ទោះបីជាលក្ខន្តិកៈ និងបទបញ្ញាតិត្រូវបានផ្សព្វផ្សាយហើយក៏ដោយ ក៏នៅមានសកម្មភាពល្មើសខ្លះទៀតដែរ ។ ឯគណៈកម្មាការសហគមន៍ទៀតសោធ ក៏ពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវធ្វើផែនការ និងដឹកនាំការងារសហគមន៍ បានល្អនៅឡើយដែរ ។

បន្តលើកទឹកចិត្ត បណ្តុះបណ្តាលដល់សហគមន៍ ក៏ដូចជាក្រុមគំរោង និងបណ្តាអ្នកពាក់ព័ន្ធសំខាន់ៗ ស្តីពីការតាមដានត្រួតពិនិត្យ និងវាយតំលៃនូវសកម្មភាពដែលបានធ្វើ គឺជាការងារមួយដែលត្រូវផ្តល់អាទិភាព។ ជាមួយគ្នានេះដែរត្រូវយកចិត្តទុកដាក់បង្កលក្ខណៈឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ ពិសេសផ្នែកជំនាញ និងអាជ្ញាធរមូលដ្ឋាន ឱ្យបានចូលរួមក្នុងកិច្ចការពារធនធាននេះ។ ក៏មានកត្តាផ្សេងៗគួរត្រូវគិតគូរផងដែរ ទាំងនោះមានដូចជាៈ លើកកំពស់ និងផ្សព្វផ្សាយចំណេះដឹងមូលដ្ឋាន និងបទពិសោធល្អៗទាក់ទងនឹងមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ។ ធ្វើការផ្សព្វផ្សាយរាល់ច្បាប់ បទដ្ឋាននានាដល់គ្រប់ស្រទាប់មហាជន។ បន្តពង្រឹងសមត្ថភាពអ្នកសំរបសំរួលការងារសហគមន៍ ព្រមទាំងបណ្តុះបណ្តាលបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតំរូវការស្ថានភាពបច្ចុប្បន្ន ដែលសហគមន៍ទាំងពីរកំពុងត្រូវការពង្រឹងបន្ថែមទៀត។

**តារាងឧបសម្ព័ន្ធទី ១**

## ប្រវត្តិគំរោង PMMR

គំរោងការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង (PMMR) ដែលបានការឧបត្ថមពីមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC)នៃប្រទេសកាណាដា និងអនុវត្តដោយក្រសួងបរិស្ថាន បានចាប់ផ្តើមសកម្មភាពរបស់ខ្លួននៅចុងឆ្នាំ១៩៩៧ នៅខេត្តកោះកុង។ នៅជំហានទីIគំរោងមានផ្តោតសំខាន់លើការងារកសាងទំនាក់ទំនងរវាងសហគមន៍មូលដ្ឋាន អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត សិក្សាស្វែងយល់ពីចំណេះដឹងមូលដ្ឋាន បញ្ហា និងការប្រើប្រាស់ធនធាន។ លើសពីនេះទៀត យើងក៏បានស្វែងយល់ផងដែរ អំពីដំណើរការគ្រប់គ្រងធនធាន ដែលកំពុងត្រូវបានអនុវត្តនៅនឹងកន្លែង។ ជាមួយគ្នានេះ គំរោងបានយកចិត្តទុកដាក់លើការកសាងសមត្ថភាពដល់សហគមន៍មូលដ្ឋានក៏ដូចជាអាជ្ញាធរ និងបណ្តាស្ថាប័នពាក់ព័ន្ធនានាពីទស្សនៈទាននៃការចូលរួមគ្រប់គ្រងធនធាន ដោយមានការចូលរួមតាមរយៈសិក្ខាសាលា និងទស្សនៈកិច្ចទៅកាន់គំរោងផ្សេងៗក្នុង និងក្រៅប្រទេស។

ចំណែកឯនៅជំហានទី IIគំរោងផ្តោតលើៈ

១: ដើម្បីកសាង និងវាយតំលៃយុទ្ធសាស្ត្រគ្រប់គ្រង និងរៀបចំផែនការ ដោយមានការចូលរួមសំរាប់តំបន់ការពារដែនជំរកសត្វព្រៃពាមក្រសោប និងតំបន់ Ramsar កោះកាពិ ផ្អែកលើលក្ខណៈប្រើប្រាស់ធនធានការវិភាគស្ថាប័ន ការវាយតំលៃ និងការរៀបចំផែនទីធនធានប្រកបដោយការចូលរួម។

២: ដើម្បីវាយតំលៃពីទំរង់នៃការរៀបចំអង្គការចាត់តាំង ដែលក្នុងនោះប្រជាជនមូលដ្ឋាន ចូលរួមក្នុងការគ្រប់គ្រងតំបន់ការពារដែនជំរកសត្វព្រៃពាមក្រសោប ។

៣: ដើម្បីវាយតំលៃជំរើសជីវភាពរស់នៅ ប្រកបដោយនិរន្តរភាពសំរាប់សហគមន៍ ដែលមានការពឹងអាស្រ័យខ្លាំងលើប្រព័ន្ធអេកូឡូស៊ី ព្រៃកោងកាង និងដើម្បីបន្តសាកល្បង និងធ្វើឱ្យមានជំរើសផ្សេងៗសំរាប់ការផលិតស្បៀងអាហារ និងរកចំណូល។

៤: ដើម្បីជំរុញការចូលរួមរបស់សហគមន៍នៅក្នុងកិច្ចការពារ អភិរក្ស និងតាមដានត្រួតពិនិត្យព្រៃកោងកាង និងធនធានជលផល នៅក្នុងតំបន់ការពារដែនជំរកសត្វព្រៃពាមក្រសោប តាមរយៈការអប់រំបរិស្ថាន ។

៥: ដើម្បីកសាងសមត្ថភាពក្រុមស្រាវជ្រាវគំរោង ប្រជាជនមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយនូវបញ្ហានានានៃការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយផ្អែកលើសហគមន៍ និងដើម្បីពង្រឹងទំនាក់ទំនងរវាងស្ថាប័នមូលដ្ឋានជាតិ និងអន្តរជាតិ ។

អាស័យដ្ឋានគំរោងៈ លេខ ៤៨ វុក្ខវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន

P.O Box 2298 ភ្នំពេញ .

Email: pmmr@bigpond.com.kh

ទំនាក់ទំនងៈ 1/ លោក គឹម ណុង ប្រធានគំរោង

2/ លោក និន វ៉ាន់ថា ប្រធានក្រុមស្រាវជ្រាវ

3/ លោក អ៊ុក លីឃីម

ទីតាំងអនុវត្តគំរោងៈ នៅក្នុងតំបន់ការពារដែនជំរកសត្វព្រៃពាមក្រសោប ខេត្តកោះកុង

លទ្ធផលៈ ជារួម លទ្ធផលនៃការអនុវត្តន៍កន្លងមកគឺ ប្រជាជន អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធមានការយល់ដឹងពីតំលៃនៃការរួមគ្នា ដើម្បីគ្រប់គ្រងធនធានក្នុងតំបន់របស់ខ្លួន។ ជាក់ស្តែងឡធ្យូងដែលកើតមានយ៉ាងអានាធិបតេយ្យក្នុងតំបន់ត្រូវបានបំបាត់ស្ទើរតែទាំងស្រុង ហើយអ្នកដែលធ្លាប់កាប់ព្រៃកោងកាងធ្វើធ្យូង ឥឡូវពួកគេធ្វើជាអ្នកនេសាទ ការពារ និងដាំព្រៃកោងកាងឡើងវិញ។ មកដល់ពេលនេះ (ឆ្នាំ២០០២) សហគមន៍នេសាទចំនួនបីនៅក្នុងភូមិបីត្រូវបានបង្កើតឡើងដោយមានការទទួលស្គាល់ដោយអាជ្ញាធរខេត្ត។

ដៃគូរបស់គំរោងៈ PMMR មានដៃគូការងាររបស់ខ្លួនគឺគំរោងការគ្រប់គ្រងតំបន់ឆ្នេរ (CZM) ដែលផ្តោតសំខាន់លើមុខរបរចិញ្ចឹមជីវិតរបស់សហគមន៍ និងការងាររៀបចំ និងដំណើរការរបស់សហគមន៍ និងដៃគូមួយទៀត គឺគំរោងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម(CBNRM) ដែលផ្តោតទៅលើការចងក្រងរបាយការណ៍ ករណីសិក្សារបស់គំរោង ដែលកំពុងអនុវត្ត។ លើសពីនេះទៀត យើងបានធ្វើ ការជាមួយគំរោងការចូលរួមគ្រប់គ្រងធនធានតំបន់ឆ្នេរផ្អែកលើ សហគមន៍នៅឧទ្យានជាតិព្រះសីហនុ(រាម) ដែលបានផ្តោតជាសំខាន់លើការងារបណ្តុះបណ្តាលបុគ្គលិកគំរោង ក៏ដូចជាគណៈកម្មការសហគមន៍មួយចំនួន។

គោលដៅអនាគតរបស់គំរោងៈ

បង្កើតសហគ្រប់គ្រងធនធាននៅក្នុងតំបន់ការពារដែនជំរកសត្វព្រៃពាមក្រសោប និងតំបន់ឯទៀតនៃតំបន់ឆ្នេរពិសេសខេត្តកោះកុង។ ការចងក្រងករណីសិក្សានេះផ្តល់នូវសារៈសំខាន់ជាច្រើនដល់គំរោង ដែលជារួមមានៈ ការកសាងសមត្ថភាពរបស់មន្ត្រីគំរោងនូវជំនាញរៀបចំចងក្រងករណីសិក្សា ការកត់ត្រាឡើងវិញនូវសកម្មភាពការងាររបស់ខ្លួនដែលបានធ្វើកន្លងមក និងការផ្សព្វផ្សាយការងារដល់គ្រប់មជ្ឈដ្ឋាននានា។ ការសរសេរករណីសិក្សាបានជួយឱ្យយើងរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនដែលនាំយើងឈានទៅកែលំអរការងារសំរាប់ថ្ងៃអនាគត។ ម្យ៉ាងវិញទៀត ផលប្រយោជន៍មិនមែនបានតែទៅលើមន្ត្រីគំរោងនោះទេ ប៉ុន្តែក៏បានដល់សហគមន៍មូលដ្ឋានផ្ទាល់ផងដែរ។ វាជាការកត់ត្រានូវរឿងរ៉ាវរបស់ពួកគេ (សហគមន៍) ក្នុងនោះមានបង្ហាញនូវបទពិសោធនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានជាច្រើនដំណាក់កាលនឹង ជាបទពិសោធដែលពួកគេ(សហគមន៍) ត្រូវការសំរាប់អនាគតនៃការចូលរួមគ្រប់គ្រងធនធាន។

ឧបសម្ព័ន្ធទី ២

## គំរោង ការគ្រប់គ្រងតំបន់ឆ្នេរដោយសហគមន៍ នៅរាម ក្រុងព្រះសីហនុ

### ១.ប្រវត្តិរបស់គំរោង:

គំរោងការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍នៅរាម បានបង្កើតឡើងនៅឆ្នាំ១៩៩៨ ខណៈដែលស្ថានភាពនេសាទ នៅក្នុងតំបន់នេះមានសភាពធ្ងន់ធ្ងរទៅៗ។ ការគ្រប់គ្រងឧទ្យានជាតិ ដែលមានទាំងដីគោក និងទឹកផងនោះពុំបានទទួលជោគជ័យណាស់ណានោះទេ ដែលបណ្តាលមកពីកង្វះការចូលរួមពីបណ្តាអ្នកពាក់ព័ន្ធនៅជុំវិញឧទ្យានជាតិ។ ដោយឃើញបញ្ហាដូចនេះ ខាងឧទ្យានជាតិបានធ្វើ ការសិក្សាមួយពីលទ្ធភាពនៃការដាក់បញ្ចូលអ្នកពាក់ព័ន្ធ ពិសេសអ្នកនេសាទទៅក្នុងកិច្ចគ្រប់គ្រងឧទ្យានជាតិ ដោយផ្តោតជាពិសេសលើការគ្រប់គ្រងធនធាននេសាទ ទីដែលពួកគេធ្លាប់នេសាទពីដូនតា មក។ ក្រោយពីបានពិភាក្សាពីគំនិតខាងលើមក ឃើញថាអ្នកភូមិខ្លះបានស្ម័គ្រចិត្ត ចូលរួមល្បាតជាមួយឧទ្យានុរក្សដែលនៅពេលជាមួយគ្នានោះ ការរៀបចំក្រុម ការជ្រើសរើសគណៈកម្មការសហគមន៍ ក៏បានចាប់ផ្តើមដំណើរការ។ រួចហើយគេក៏បានរៀបចំតាក់តែងលក្ខន្តិកៈនិងបញ្ញត្តិរបស់សហគមន៍។ ជាដំបូងដំណើរការធ្វើឡើងនៅភូមិចំនួន៥ ដែលរហូតដល់ឆ្នាំ២០០១ ចំនួនភូមិបានឡើងដល់ទៅ ១០ ដែលចំនួនអ្នកចូលរួម៦២០គ្រួសារ។

មានអ្នកជួយឧបត្ថម្ភផ្សេងៗគ្នាដល់ដំណើរការរៀបចំសហគមន៍នៅឧទ្យានជាតិរាម។ ពីឆ្នាំ១៩៩៥ ដល់ ១៩៩៩ គំរោង Environmental Technical Advisory Programme (ETAP/UNDP) បន្ទាប់មកគឺពីឆ្នាំ១៩៩៩ ដល់ ២០០០ Wetlands International (WI) និងបន្តដោយ Coastal Zone Management (CZM/DANIDA) រហូតដល់ ខែកក្កដា ២០០២។ គំរោង PMMR/IDRC ក៏បានចូលរួមដែរ ដោយផ្តោតជាពិសេសលើការកសាងសមត្ថភាព។

**២.គោលបំណងរួម:** លើកកំពស់ការចូលរួមគ្រប់គ្រងធនធានតំបន់ឆ្នេរពីអ្នកពាក់ព័ន្ធ ពិសេសអ្នកនេសាទ និងកែលំអរការជីវភាពរស់នៅរបស់ប្រជានេសាទនៅក្នុងតំបន់។

### ៣.គោលបំណងជាក់លាក់:

- រៀបចំសហគមន៍ និងសហគ្រប់គ្រងធនធានតំបន់ឆ្នេរ
- លើកកំពស់ការយល់ដឹងពីបរិស្ថានដល់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត។
- បង្កើនមុខរបរដល់សមាជិកសហគមន៍ ។

### ៤.បុគ្គលិកគំរោង

មានអ្នកសំរបសំរួលចំនួន៦នាក់ ធ្វើការនៅទីនេះ មាន: មន្ត្រីជំនាញមកពីក្រសួងបរិស្ថានចំនួន២ នាក់ មន្ត្រីការិយាល័យ ជលផលក្រុងព្រះសីហនុ ១នាក់ បុគ្គលិកឧទ្យានជាតិព្រះសីហនុ "រាម" ចំនួន ៣នាក់។

### ៥.លទ្ធផលនៃការអនុវត្តន៍គំរោង:

- តាមការពិភាក្សាជាមួយសមាជិកសហគមន៍បានឱ្យដឹងថា ប្រហែលជា៨០% នៃបទល្មើសបានថយចុះ ឯផលចាប់ក៏ មានការកើនឡើងខ្លះដែរ ពិសេសការនេសាទដោយដៃ( រាវគ្រែង បង្គា លូកក្តាម) និងការរុញឈីបដោយដៃ។
- ដោយផលចាប់នៅក្នុងដែនសហគមន៍មានការកើនឡើងធ្វើឱ្យ អ្នកខ្លះដែលធ្លាប់តែរកស៊ីនេសាទខាងក្រៅបាន ប្តូរឧបករណ៍មកនេសាទក្នុងដែនសហគមន៍ដែរ។
- សហគមន៍បានទទួលការគាំទ្រកាន់តែទូលំទូលាយពី ស្ថាប័នពាក់ពន្ធ័ជុំវិញ និងអាជ្ញាធរមូលដ្ឋាន ជាពិសេស ក្រុមការងារថ្នាក់ខេត្ត។

## ៦. ដៃគូរបស់គំរោង

គំរោង WWF/ CBNRM ជាពិសេស គំរោង PMMR ក្នុងការពង្រឹងសមត្ថភាពសហគមន៍ និង បុគ្គលិកគំរោង ដោយមាន រៀបចំជាសិក្ខាសាលា និងវគ្គបំប៉នអំពីការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយមានការចូលរួម និងការចងក្រង ករណីសិក្សា ព្រមទាំងរៀបចំ អោយមានកម្មវិធី ទស្សនៈកិច្ចសិក្សាដកស្រង់បទពិសោធន៍អំពីសហគមន៍នៅតំបន់ផ្សេងៗ ។

## ៧.អស័យដ្ឋានទំនាក់ទំនង

ទីស្នាក់ការឧទ្យានជាតិព្រះសីហនុ "រាម"

លោក ស៊ុយ ធា អ្នកសំរបសំរួលគំរោង

TeL: (855) 12915-090

## ឧបសម្ព័ន្ធទី៣ ៖ គំរោងករណីសិក្សាការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម

ករណីសិក្សាស្តីពី "ការចូលរួមគ្រងធនធានធម្មជាតិដោយមានការចូលរួម ត្រូវបានសំរបសំរួលដោយស្ថាប័នចំរុះ និងក្រុមស្នូលស្រាវជ្រាវនៅ ក្នុងប្រទេសកម្ពុជា ព្រមទាំងដៃគូសហការផ្សេងៗ។ ជាងនេះមានសមាសភាពចូលរួមពីស្ថាប័នផ្សេងៗដូចជា ស្ថាប័នរាជរដ្ឋាភិបាល ក្រុមអង្គការ ស្ថាប័នបណ្តុះបណ្តាល និងសហគមន៍មូលដ្ឋាន សង្គមស៊ីវិលដែលកំពុងបានអនុវត្តការងារនៅតំបន់ខ្ពង់រាប ទំនាបកណ្តាល តំបន់មេគង្គ ព្រមទាំងតំបន់ឆ្នេរ។

*គំរោងស្តីពី " ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" ត្រូវបានឧបត្ថម្ភ ដោយអង្គការមួយចំនួនដូចជា ៖*

- ✓ –អង្គការកម្មវិធីអភិរក្សធនធានធម្មជាតិពិភពលោក
- ✓ -អង្គការមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិសំរាប់ការអភិវឌ្ឍន៍
- ✓ -អង្គការមជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់
- ✓ -អង្គការបណ្តុះបណ្តាល ស្រាវជ្រាវ និងបណ្តាញការងារនៅបំបន់មេគង្គ

គំរោងនេះបានគាំទ្រដល់ទំនាក់ទំនងជាមូលដ្ឋានដែលបានអនុម័ត ផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន ដើម្បីចូលរួមយ៉ាងសកម្មក្នុងការអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាពដោយឆ្លងកាត់៖

- ✓ -សហគមន៍ព្រៃឈើ
- ✓ -សហគ្រប់គ្រងធនធានជលផល
- ✓ -ការចូលរួមធ្វើផែនការប្រើប្រាស់ដី ការចូលរួមគ្រប់គ្រងក្នុងតំបន់ការពារ។

ទិសដៅទូទៅរបស់គំរោងនេះ គឺជួយជំរុញអោយការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ស្ថិតនៅជាផ្នែកមួយយ៉ាងពិតប្រាកដនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។

គោលបំណងជាក់លាក់របស់គំរោងគឺ

- ✓ - ការកសាងសមត្ថភាព - រៀនសូត្រពីបទពិសោធន៍
- ✓ - បណ្តាញការងារ - ការគាំទ្រគោលនយោបាយ
- ✓ សកម្មភាពបន្ទរបស់កម្មវិធីគំរោងរួមមានការបង្កើតឡើងនូវទស្សនៈសំខាន់ៗព្រមទាំងការវិភាគលើគ្រោងការណ៍សំរាប់អនុវត្តលើគំរោង "ការចូលរួមគ្រប់គ្រងធនធាន ធម្មជាតិដោយមានការចូលរួម" នៅកម្ពុជា។ ជាងនេះការកសាងសមត្ថភាពដោយឆ្លងកាត់ការអនុវត្តសរសេររបាយការណ៍ករណីសិក្សា ដើម្បីបង្កើនការស្រាវជ្រាវ ការរៀបចំ ឯកសារ ជំនាញវិភាគ និងការកសាងបណ្តាញការងាររវាងអ្នកគាំទ្រ "ការគ្រប់គ្រង ធនធានធម្មជាតិដោយមានការចូលរួម" ទូទាំងប្រទេស និងថ្នាក់តំបន់ព្រមទាំងការគាំទ្រ នូវដំណើរការពិគ្រោះយោបល់សំរាប់ការអភិវឌ្ឍន៍គ្រោងការណ៍ពាក់ពន្ធ័ស្របច្បាប់។

### អង្គការដែលជាដៃគូអនុវត្តការងារជាមួយគំរោង "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម"

- ✓ នាយកដ្ឋានអភិរក្ស និងការពារធនធានធម្មជាតិ( ក្រសួងបិស្ថាន)
- ✓ នាយកដ្ឋានរុក្ខាប្រមាញ់ និងសត្វព្រៃ ( ក្រសួងកសិកម្ម)
- ✓ នាយកដ្ឋានជលផល( ក្រសួងកសិកម្ម)
- ✓ អង្គការមូលនិធិសំរាប់ធនធានធម្មជាតិ
- ✓ មជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិសំរាប់ការអភិវឌ្ឍន៍
- ✓ មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់
- ✓ អង្គការបណ្តុះបណ្តាល ស្រាវជ្រាវ និងបណ្តាញការងារនៅបំបន់មេគង្គ
- ✓ អង្គការអុកស្វាមអាមេរិកាំង
- ✓ គំរោងស្តីពី ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាងនៅតំបន់ឆ្នេរ
- ✓ តំបន់ឧទ្យានជាតិរាម នៃក្រុងព្រះសីហនុ
- ✓ អង្គការខុនសឺន
- ✓ អង្គការជំនួយសហគមន៍បរទេសនៃអុកស្វាម(ស្ទឹងត្រែង)
- ✓ គំរោងស្តីពី" ការស្រាវជ្រាវសហគមន៍ព្រៃឈើ"
- ✓ គំរោងស្តីពី"អនុផលព្រៃឈើ" (រតនៈគិរី)
- ✓ គំរោងស្តីពី" អភិបាលកិច្ច សំរាប់ភាពជាដៃគូ"
- ✓ អង្គការហ្វាវ ( សៀមរាប)
- ✓ សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- ✓ សាកលវិទ្យាល័យភ្នំពេញ ( មហាវិទ្យាល័យ នៃវិទ្យាសាស្ត្របរិស្ថាន)
- ✓ ក្រុមការងារហគមន៍ព្រៃឈើ
- ✓ ក្រុមការងារសំរាប់ច្បាប់ជលផល
- ✓ ក្រុមការងារបណ្តុះបណ្តាលផែនការចូលរួមគ្រប់គ្រងដីធ្លី
- ✓ បណ្តាញការងារសហគមន៍ព្រៃឈើ
- ✓ វេទិការរបស់អង្គការក្រៅរដ្ឋាភិបាល ស្តីពីបរិស្ថាន

# CBNRM Organizational Profile

***CBNRM Learning Initiative***

The CBNRM Case Studies and Networking Initiative is facilitated by a cross-institutional, multi-disciplinary core group of researchers in Cambodia, with partners from various levels and departments of government, NGOs, networks, learning institutions, communities and other civil society groups working in Upland, Lowland, Mekong and Coastal areas.

The project supports linkages to locally based approaches that empower local communities to participate actively in the conservation and sustainable management of natural resources through:

- Community Forestry
- Co-Management of Fisheries
- Participatory Land Use Planning
- Participatory Protected Areas Management

The overall goal of the project is to promote CBNRM as an integral component of the socio-economic development policies and strategies of the Royal Government of Cambodia (RGC). Specific objectives and challenges of this initiative include:

1. Capacity Building
2. Lessons Learning
3. Networking
4. Policy Support

Ongoing activities of the program include the development of a conceptual and analytical framework for Cambodia-based CBNRM, as well as capacity building through case study writing to enhance research, documentation, and analysis skills, networking of CBNRM supporters throughout the country and in the region, and supporting the consultative process for the development of relevant policy and legal frameworks.

CBNRM PARTNER ORGANIZATIONS:

- Community Forestry and Buffer Zone Management Office
- Department of Nature Conservation & Protection, MoE
- Community Forestry Unit
- Department of Forestry and Wildlife, MAFF
- Community Fisheries Development Office (CFDO)
- Department of Fisheries, MAFF

- WWF
- Oxfam America
- IDRC
- RECOFTC
- LeaRN
- Mekong Learning Initiative

- Participatory Management of Mangrove Resources (PMMR)
- Ream National Park, Sihanoukville
- Concern Worldwide
- FAO Siem Reap
- OCAA Stung Treng
- Community Forestry Research Project (CFRP)
- Non Timber Forest Projects (NTFP)
- Partnership for Local Governance, Ratanakiri (PLG/ IDRC)
- MOSAIC, Mondulkiri
- GTZ-CGFP
- Royal University of Agriculture, Forestry and Fisheries Faculties
- Royal University of Phnom Penh, Faculty of Environmental Science

- Community Forestry Working Group
- Fisheries Law Working Group
- PLUP Training Team
- CF Network
- NGO Forum on Environment

**Key Co-Supporters:**

World Wide Fund for Nature (WWF)

Oxfam America

International Development Research Centre (IDRC)

Regional Community Forestry Training Center (RECOFTC)

CBNRM Initiative

**Learning Cycle of CBNRM**





**Contact Information:**

CBNRM Learning Initiative
c/o World Wide Fund for Nature
#28 Street 9 Tonle Bassac
Phnom Penh, Kingdom of Cambodia
Tel: (855-23) 218034
Mobile: (855-12) 962 092
